Disability Rights California

*ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# សន្លឹកព័ត៌មានការពិតស្តីអំពីការបិទសំណុំរឿងសេវាកម្មស្តានីតិសម្បទាវិជ្ជាជីវៈ

*ខែវិច្ឆិកា ឆ្នាំ2015 ឯកសារបោះពុម្ពផ្សាយលេខ F074.06 - Cambodian*

## តើវាមានន័យដូចម្តេចនៅពេលនាយកដ្ឋានស្តានីតិសម្បទា (DOR, Department of Rehabilitation) និយាយថាសំណុំរឿងរបស់ខ្ញុំត្រូវបានបិទ?

ការបិទសំណុំរឿង គឺនៅពេលដែល DOR សម្រេចថា គេឈប់ផ្តល់សេវាកម្មស្តានីតិសម្បទាឲ្យអ្នកទៀតហើយ ។ Title 9 នៃក្រមនិយត្តកម្មរដ្ឋកាលីហ្វ័រនីញ៉ា (C.C.R., California Code of Regulations) ចាប់ពីវគ្គ 7179 ដល់វគ្គ 7181.1 បានកំណត់អំពីការទទួលខុសត្រូវរបស់ DOR និងការទទួលខុសត្រូវរបស់អតិថិជន ពាក់ព័ន្ធនឹងការបិទសំណុំរឿង ។

## តើ DOR អាចបិទសំណុំរឿងរបស់ខ្ញុំនៅពេលណា?

គិតតាមច្បាប់ DOR អាចបិទសំណុំរឿងរបស់អ្នកបាននៅពេល ៖

- អ្នកបានសម្រេចគោលបំណងការងាររបស់ខ្លួន ហើយអ្នកលែងត្រូវការសេវាកម្មរបស់ DOR ដើម្បីអាចរក្សាការងាររបស់ខ្លួនទៀតហើយ ហើយ DOR បានផ្តល់ឲ្យអ្នកទាំងអស់នូវសេវាកម្ម ទៅតាមការព្រមព្រៀង ដូចមានចែងនៅក្នុងផែនការតម្រូវតាមលក្ខណៈបុគ្គលសម្រាប់ការងារ (IPE, Individualized Plan for Employment) របស់អ្នក
- អ្នកត្រូវបានគេរកឃើញថា មានសិទ្ធិទទួលសេវាកម្មពី DOR អាស្រ័យលើលក្ខណៈវិនិច្ឆ័យជាក់លាក់ ប៉ុន្តែទាំងថា ពិការភាពរបស់អ្នកមានភាពធ្ងន់ធ្ងរពេក ដែលថាអ្នកមិនអាចទទួលបានផលប្រយោជន៍ពីសេវាកម្មរបស់ DOR ឡើយ

- អ្នកជ្រើសរើសមិនចូលរួមក្នុងកម្មវិធីរបស់ DOR ឬមួយអ្នកមិនអាចចូលរួមក្នុងកម្មវិធីរបស់ DOR បានដោយមានមូលហេតុផ្សេងៗ ។ ឧទាហរណ៍ មានដូចជាអ្នកមានបញ្ហាសុខភាពធ្ងន់ធ្ងរ ដែលបង្ការអ្នកមិនឲ្យចូលរួមក្នុងកម្មវិធីរបស់ DOR បើទោះបីជាមានការសម្រួលសមរម្យក៏ដោយ បើអ្នកបដិសេធ ឬមិនអាចចូលរួមបានទៅតាមភាពតម្រូវនៃការវាយតម្លៃរបស់ DOR សម្រាប់គោលបំណងកំណត់ពីភាពមានសិទ្ធិទទួលជំនួយ ប្រសិនបើ DOR មិនមានព័ត៌មានសម្រាប់ទំនាក់ទំនង ហើយពួកគេមិនអាចរកអ្នកឃើញ បើអ្នកកំពុងស្ថិតនៅក្នុងមន្ទីរណាមួយ ដូចជានៅមន្ទីរពេទ្យ ឬពន្ធនាគារ ក្នុងរយៈពេលវែង ឬថាអ្នកជាប់ពាក់ព័ន្ធនឹងសកម្មភាពឧក្រិដ្ឋកម្ម ក្នុពេលអ្នកកំពុងតែទទួលបាន សេវាកម្មរបស់ DOR ។

## តើខ្ញុំអាចដឹងបានដោយរបៀបណាថា DOR បិទសំណុំរឿងរបស់ខ្ញុំ?

DOR ត្រូវផ្ញើឲ្យអ្នកនូវការជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីប្រាប់អ្នកថា សំណុំរឿងរបស់អ្នកត្រូវបានបិទ ។ សេចក្តីជូនដំណឹងនោះត្រូវមានបង្ហាញព័ត៌មានពីមូលហេតុដែលសំណុំរឿងរបស់អ្នកត្រូវបិទ ព័ត៌មានអំពីសិទ្ធិប្តឹងឧទ្ធរណ៍របស់អ្នក បូករួមទាំងសិទ្ធិទទួលបានការសម្រុះសម្រួល ការពិនិត្យសំណុំរឿងឡើងវិញតាមបែប រដ្ឋបាល ដំណើរការសវនាការយុត្តិធម៌ និងព័ត៌មានអំពីកម្មវិធីសម្រាប់ផ្តល់ជំនួយដល់អតិថិជន (CAP, Client Assistance Program) ។

## តើខ្ញុំអាចធ្វើអ្វីបាន បើខ្ញុំមិនយល់ព្រមជាមួយនឹងសេចក្តីសម្រេចរបស់ DOR អំពីការបិទសំណុំរឿងរបស់ខ្ញុំ?

DOR មានកម្រិតផ្សេងៗចំពោះការប្តឹងឧទ្ធរណ៍ ។ កម្រិតទីមួយនៃការប្តឹងឧទ្ធរណ៍គឺការពិភាក្សាជាមួយនឹងអ្នកប្រឹក្សាយោបល់ផ្នែកស្តានីតិសម្បទារបស់អ្នក និង/ឬប្រធានរបស់អ្នកប្រឹក្សាយោបល់របស់អ្នក អំពីការបិទសំណុំរឿងរបស់អ្នក ។ ដំណើរការនេះអាចដោះស្រាយបាន ឧទាហរណ៍ ពេលដែលសំណុំរឿង DOR របស់អ្នកត្រូវបានបិទ ដោយសារគេរកអ្នកមិនឃើញ តែក្រោយមកអ្នកបានមកទាក់ទងជាមួយនឹង DOR ឡើងវិញ ឬ ក្នុងស្ថានភាពដែលថា ការពិតអ្នកកំពុងធ្វើតែមានការរីកចម្រើនទៅកាន់គោលបំណង IPE របស់អ្នក តែ DOR

មិនបានដឹងពីស្ថានភាពនេះ ។ DOR អាចត្រូវពិនិត្យឡើងវិញពីការបិទសំណុំរឿងរបស់អ្នក បើមានការស្នើសុំពីអ្នក ហើយសំណុំរឿងរបស់អ្នកត្រូវបានបិទក្នុងពេល 12 ខែមុន ។ នៅក្នុងស្ថានភាពខ្លះ DOR អាចយល់ព្រមបើកសំណុំរឿងរបស់អ្នកឡើងវិញ បើអ្នកអាចបង្ហាញថា អ្នកបានត្រៀមខ្លួនរួចរាល់ក្នុងការធ្វើឲ្យមានការរីកចម្រើនទៅកាន់គោលបំណង IPE របស់អ្នក ឬអ្នកបានត្រៀមខ្លួនរួចរាល់ដើម្បីធ្វើតាមសំណើរបស់ DOR ។

បើអ្នកមិនយល់ព្រមជាមួយនឹងការសម្រេចរបស់ DOR ចំពោះការបិទសំណុំរឿងរបស់អ្នក អ្នកក៏អាចស្នើសុំឲ្យមានការពិនិត្យឡើងវិញតាមបែបរដ្ឋបាលជាមួយនឹងរដ្ឋបាលស្រុក (District Administrator) នៃ DOR ស្នើសុំការសម្រុះសម្រួល និង/ឬស្នើសុំសវនាការយុត្តិធម៌ ក្នុងរវាងមួយឆ្នាំនៃការសម្រេចរបស់ DOR ។ សម្រាប់ព័ត៌មានបន្ថែមស្ដីអំពីសិទ្ធិសវនាការរបស់អ្នក និងបន្ទាត់ពេលវេលាដែលអាចប្រើបានក្នុងស្ថានភាពរបស់អ្នក សូមចូលទៅកាន់អាសដ្ឋានភ្ជាប់ទៅកាន់ DOR ៖ http://www.rehab.cahwnet.gov/Appeals/FairHearForms.html#DR107 ។

## តើខ្ញុំអាចដាក់ពាក្យសុំសេវាកម្មពី DOR ឡើងវិញបានទេ ក្រោយពេលសំណុំរឿងរបស់ខ្ញុំត្រូវបានបិទ?

បាន ។ អ្នកអាចដាក់ពាក្យស្នើសុំសេវាកម្មឡើងវិញបាន បើអ្នកត្រូវការសេវាកម្មពី DOR ម្ដងទៀត ។ DOR នឹងត្រូវធ្វើការកំណត់សិទ្ធិទទួលជំនួយរបស់អ្នកឡើងវិញ និងជួយអ្នកក្នុងការបង្កើតថ្មីនូវ IPE ។

DOR ក៏អាចយកព័ត៌មានក្នុងសំណុំរឿងពីមុនមកពិចារណាផងដែរ ក្នុងការកំណត់ភាពមានសិទ្ធិទទួលសេវាកម្មរបស់អ្នក នៅពេលអ្នកដាក់ពាក្យសុំសេវាកម្មពី DOR ឡើងវិញ ។ សម្រាប់ព័ត៌មានបន្ថែមស្ដីអំពីភាពមានសិទ្ធិទទួលជំនួយពី DOR សូមអានសន្លឹកការពិតរបស់ CAP ដែលមានចំណងជើងថា Eligibility for Vocational Rehabilitation Services តាមអាសយដ្ឋាន ៖ http://www.disabilityrightsca.org/pubs/06601.pdf

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្ដល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្ដល់ជំនួយ សូម*

*ទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html.